**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
-សំណុំរឿងព្រហ្មទណ្ឌលេខៈ១២២៦
ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខៈ ៨៥៩
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខៈ ១១០៥
ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២
-សាលក្រមព្រហ្មទណ្ឌលេខៈ ៨០(ត)
ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣។
ប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣។
ដោយមានសមាសភាពជំនុំជម្រះដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ឋានៈជាចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកំពង់ស្ពឺ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ស្ពឺ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១២២៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ដែលមានដូចខាងក្រោម ៖

**ជនជាប់ចោទ**

១-ឈ្មោះ [redacted] ស៊ើ ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ស្ពឺ មានទីលំនៅមុនពេលចាប់ខ្លួនភូមិ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] សាវ (រស់) ម្តាយឈ្មោះ [redacted] សាន (ស្លាប់) ប្តីឈ្មោះ[redacted] សៅ មានកូន០៣នាក់ ជានីតិជន ទោសពីមុនគ្មាន អត់បានរៀន។

-ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ស្ពឺ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៣ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

២-ឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ស្ពឺ មានទីលំនៅមុនពេលចាប់ខ្លួន ភូមិ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted] គង់ (រស់) ម្តាយឈ្មោះ[redacted] យ៉ាត់ (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន រៀនថ្នាក់ទី៩ ។

-ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ស្ពឺ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៤ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

៣-ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ស្ពឺ មានទីលំនៅមុនពេលចាប់ខ្លួន ភូមិត្រ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ហេន (រស់) ម្ដាយឈ្មោះ [redacted] ណោន (រស់) ប្ដីឈ្មោះ [redacted] សុជាតិ មានកូន០២នាក់ ជានីតិជន ទោសពីមុនគ្មាន រៀនថ្នាក់ទី៤ ។

-ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ស្ពឺ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៥ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

៤-ឈ្មោះ [redacted] ទូច ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅភូមិត្រ[redacted] ខេត្តកំពង់ស្ពឺ មានទីលំនៅមុនពេលចាប់ខ្លួនភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ញ៉ែត (ស្លាប់) ម្ដាយឈ្មោះ [redacted] ឡាត់ (រស់) ប្ដីឈ្មោះ [redacted] ថុន មានកូន០៣នាក់ ជានីតិជន ទោសពីមុនគ្មាន អត់បានរៀន។

-ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ស្ពឺ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

ជាប់ចោទពីបទ ៖ **បើកកន្លែងលេងល្បែងស៊ីសង និងលេងល្បែងស៊ីសង** ប្រព្រឹត្តនៅចំណុចភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥ និងមាត្រា៤ នៃច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង។

-អមដោយលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១៧ និង១០ នាទី ស្ថិតនៅចំណុចផ្ទះរបស់ឈ្មោះ [redacted] សើ ស្ថិតនៅភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ មានករណីសមត្ថកិច្ចបានចុះបង្ក្រាបករណីលេងល្បែងស៊ីសងខុសច្បាប់ និងឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] សើ , ឈ្មោះ [redacted] អាង ,ឈ្មោះ [redacted] ទូច និងឈ្មោះ [redacted] វុធ ព្រមទាំងដកហូតវត្ថុតាងដូចជា បៀរចំនួន ២ ហ៊ូ និងប្រាក់រៀលចំនួន ៦១,០០០រៀល (ទទួលជាក់ស្ដែង ២១,០០០រៀល)។ ក្រោយពេលធ្វើការសាកសួរឃើញថា អ្នកទាំងបួននាក់ខាងលើពិតជា ជាប់ពាក់ព័ន្ធនឹងករណីល្បែងស៊ីសងប្រាកដមែន។

-បានឃើញ: របាយការណ៍លេខ: ២៩៥ រ.ប.ក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ការិយាល័យ នគរបាលព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការនគរបាលខេត្តកំពង់ស្ពឺ។

-បានឃើញ:ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ៨១២០ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ:ដីកាសន្និដ្ឋានស្ថាពរលេខ: ៨៥៩២ ដ.ស.៣/២២ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ:ដីកាដំណោះស្រាយលេខ: ៨៩៨ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ: ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១២៥៦ ដចជ រ.ប/២២ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញៈ លិខិតជូនដំណឹង និងចាត់តាំងតំណាងអយ្យការលេខៈ ៣៥ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ របស់លោកជំទាវព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

**នាពេលពិភាក្សាដេញដោល**

-ជនជាប់ចោទឈ្មោះ [redacted] សើ, [redacted] វុធ, [redacted] អាង និងឈ្មោះ [redacted] ទូច មានវត្តមាន។

-លោកមេធាវី [redacted] ជាមេធាវីការពារផលសិទ្ធិឱ្យជនជាប់ចោទ មានវត្តមាន។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សើ បានឆ្លើយសារភាពថាៈ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ នៅផ្ទះរបស់ខ្លួន ស្ថិតនៅភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយដកហូតបានបៀរចំនួន១ហ៊ូ។សមត្ថកិច្ចឃាត់ខ្លួនរូបខ្លួននៅពេលដែលខ្លួនត្រលប់មកពីផឹកស៊ីភូមិត្រពាំងក្រួច ឃុំនរាយណ៍ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ ខ្លួនពុំដឹងថាឈ្មោះ [redacted] វុធ , ឈ្មោះ [redacted] ទូច ,ឈ្មោះ [redacted] អាង និងឈ្មោះ ពៅ លេងបៀរនៅផ្ទះរបស់ខ្លួននោះទេ ព្រោះខ្លួនទៅធ្វើម្ហូបផឹកស៊ីនៅផ្ទះរបស់បងខ្លួននៅភូមិត្រពាំងក្រួចឯនោះ។ ខ្លួនមិនបានលេងល្បែងនោះទេ។ ថ្ងៃលេងល្បែងនោះ គឺមានគ្រួសាររបស់ខ្លួននៅផ្ទះដែរ។ ប៉ុន្តែខ្លួនមិនបានដឹងថាអ្នកណាលេង ឬមិនលេងនោះទេ ព្រោះខ្លួនមិនបាននៅផ្ទះ។ ខ្លួនមិនបានបើកកន្លែងលេងល្បែងស៊ីសងនោះទេ ហើយការលេងល្បែងនេះ គឺប្អូនថ្លៃខ្លួន និងអ្នកជិតខាងគ្រាន់តែលេង ដើម្បីសប្បាយជួបជុំបងប្អូនប៉ុណ្ណោះ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វុធ បានឆ្លើយសារភាពថាៈ សមត្ថកិច្ចឃាត់រូបខ្លួនកាលពីថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២២ នៅផ្ទះរបស់ឈ្មោះ [redacted] សើ ស្ថិតនៅភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយពុំមានដកហូតវត្ថុតាងអ្វីទេ។ សមត្ថកិច្ចឃាត់រូបខ្លួនខណៈពេលដែលខ្លួនកំពុងលេងបៀរស៊ីគូថៃ មួយទឹក៥០០រៀល ជាមួយឈ្មោះ [redacted] អាង ,ឈ្មោះ [redacted] ទូច និងម្នាក់ទៀតមិនស្គាល់ឈ្មោះ។ ចំណែកម្ចាស់ផ្ទះឈ្មោះ [redacted] សើ ពុំដឹងថាពួកខ្លួនមកលេងបៀរទេ ព្រោះគាត់ទៅផឹកស៊ីនៅភូមិត្រពាំងក្រួច ឃុំនរាយណ៍។ ខ្លួនជាអ្នកបបួលពួកគាត់លេង លុះពេលឈ្មោះ [redacted] ង សើ ត្រលប់មកវិញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ក្នុងរឿងនេះឈ្មោះ [redacted] សើ មិនបានដឹងរឿងអ្វីនោះទេ។ ខ្លួនមិនដែលទៅលេងបៀផ្ទះគាត់ទេ ទើបតែលើទី១ប៉ុណ្ណោះ ខ្លួនលេងល្បែងនេះគឺគ្រាន់តែលេងដើម្បីសប្បាយពេលជួបជុំបងប្អូនបណ្ណោះ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អាង បានឆ្លើយសារភាពថាៈ សមត្ថកិច្ចឃាត់រូបខ្លួនកាលពីថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២២ នៅផ្ទះរបស់ឈ្មោះ [redacted] សើ ស្ថិតនៅភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយបានដកហូតបានប្រាក់រៀលចំនួន ២៨,០០០ រៀល សមត្ថកិច្ចឃាត់រូបខ្លួនខណៈពេលដែលខ្លួនកំពុងលេងបៀរស៊ីគូថៃ មួយទឹក៥០០រៀល ជាមួយបងប្អូនរបស់ខ្លួនឈ្មោះ [redacted] វុធ ,ឈ្មោះ [redacted] និង ឈ្មោះ ទូច។ ចំណែកម្ចាស់ផ្ទះឈ្មោះ [redacted] សើ ពុំដឹងថាពួកខ្លួនមកលេងបៀរទេ ព្រោះគាត់ទៅផឹកស៊ីនៅភូមិត្រពាំងក្រួច ឃុំនរាយណ៍។ លុះពេលឈ្មោះ [redacted] សើ ត្រលប់មកវិញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ឈ្មោះ [redacted] សើ មិនបានលេងបៀជាមួយពួកខ្លួនទេ ហើយក៏មិនបានដឹងថាពួកខ្លួនលេងបៀរនៅផ្ទះរបស់គាត់ដែរ ប៉ុន្តែពេលលេងនោះ គឺមានគ្រួសារគាត់នៅទីនោះដែរ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទូច បានឆ្លើយសារភាពថាៈ សមត្ថកិច្ចឃាត់រូបខ្លួនកាលពីថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២២ នៅផ្ទះរបស់ឈ្មោះ [redacted] សើ ស្ថិតនៅភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយបានដកហូតបានប្រាក់រៀលចំនួន ១៣,០០០ រៀល។

សមត្ថកិច្ចឃាត់ខ្លួនខណៈពេលដែលខ្លួនកំពុងលេងបៀរស៊ីគូថៃ មួយទឹក៥០០រៀល ជាមួយបងប្អូនរបស់ខ្លួនឈ្មោះ [redacted]វុធ ,ឈ្មោះ [redacted] អាង និង ឈ្មោះ ៣។ ខ្លួនពុំដឹងថាម្ចាស់ផ្ទះឈ្មោះ [redacted] ស៊ើ ដឹងថាពួកខ្លួនទៅលេងបៀផ្ទះគាត់ឬអត់ទេ ព្រោះពេលនោះគាត់អត់នៅផ្ទះទេ ដោយគាត់ទៅជីកស៊ីនៅភូមិត្រពាំងក្រូច ឃុំនរាយណ៍។ លុះពេលឈ្មោះ [redacted] ស៊ើ ត្រលប់មកវិញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានៈ** ឆ្លងតាមការសួរដេញដោលនាពេលសវនាការក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ ការសន្និដ្ឋានរបស់មន្ត្រីនគរបាលយុត្តិធម៌ និងពិនិត្យមើលអង្គហេតុរួចមក ឃើញថាមានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ស៊ើ ភេទស្រី អាយុ៤២ឆ្នាំ ,ឈ្មោះ [redacted]វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទូច ភេទស្រី អាយុ៤៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **បើកកន្លែងលេងល្បែងស៊ីសង និងលេងល្បែងស៊ីសង** ប្រព្រឹត្តនៅចំណុចភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥ និងមាត្រា៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ប្រាកដមែន។ ដូច្នេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៨៥៩២ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ទុកនៅដដែល និងប្តឹងសុំឱ្យចៅក្រមជំនុំជម្រះពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

**-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ** ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយឆ្លើយសារភាពរបស់ជនជាប់ចោទ ការសន្និដ្ឋានរបស់មន្ត្រីនគរបាលយុត្តិធម៌ និងពិនិត្យមើលអង្គហេតុរួចមក ឃើញថាកូនក្តីរបស់ខ្ញុំបាទពិតជាបានសារភាពថា ខ្លួនពិតជាបានលេងល្បែងស៊ីសង ពិតប្រាកដមែន។ ដូច្នេះខ្ញុំបាទស្នើសុំឱ្យតុលាការមេត្តាឱ្យកូនក្តីខ្ញុំបាទឈ្មោះ [redacted] ស៊ើ រួចខ្លួនពីបទចោទ និងសុំឱ្យតុលាការផ្តល់ស្ថានសម្រាលទោសដល់កូនក្តីឈ្មោះ [redacted] ទូច, [redacted] អាង, [redacted] វុធ និងដោះលែងឱ្យកូនក្តីខ្ញុំបាទបានត្រលប់ទៅផ្ទះវិញផង ដោយកូនក្តីខ្ញុំបាទបានដឹងកំហុសហើយ និងសន្យាថាឈប់ប្រព្រឹត្តអំពើខុសច្បាប់តទៅទៀតហើយ។

-ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលរួចរាល់ហើយ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យកំណត់ហេតុ ឯកសារភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់។

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខៈ ១២២៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ មកជំនុំជម្រះក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៨៥៨ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយបានបញ្ជូនជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] ស៊ើ ភេទស្រី អាយុ៤២ឆ្នាំ ,ឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទូច ភេទស្រី អាយុ៤៨ឆ្នាំ មកជំនុំជម្រះពីបទៈ បើកកន្លែងលេងល្បែងស៊ីសង និងលេងល្បែងស៊ីសង ប្រព្រឹត្តនៅចំណុចភូមិត្រពាំង

ឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ និងមាត្រា៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២-យោងតាមរបាយការណ៍លេខ: ២៩៥/២២ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការនគរបាលខេត្តកំពង់ស្ពឺ បានបញ្ជាក់ថា ៖ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១៧ និង១០ នាទី ពិតជាមានអំពើ **បើកកន្លែងលេងល្បែងស៊ីសង និងលេងល្បែងស៊ីសង** ប្រព្រឹត្តនៅចំណុចភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ស៊ើ ភេទស្រី អាយុ៥២ឆ្នាំ ,ឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទូច ភេទស្រី អាយុ៤៨ឆ្នាំ ប្រាកដមែន។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៣-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ើ បានឆ្លើយសារភាពសារភាពខាងលើឃើញថា: ចម្លើយសារភាពនេះមានភាពស៊ីចង្វាក់ទៅនឹងសំណុំរឿង និងឯកសារភស្តុតាងនានាក្នុងសំណុំរឿង និងមានមូលដ្ឋានច្បាស់អាចឱ្យតុលាការជឿបានថា ពិតជាមានអង្គហេតុនៃអំពើ បើកកន្លែងលេងល្បែងស៊ីសង ដែលប្រព្រឹត្តដោយជនជាប់ចោទ ពិតប្រាកដមែន។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៤-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អាង បានឆ្លើយសារភាពខាងលើ ឃើញថា: ចម្លើយសារភាពនេះមានភាពស៊ីសង្វាក់ទៅនឹងសំណុំរឿង និងឯកសារភស្តុតាងនានាក្នុងសំណុំរឿង និងមានមូលដ្ឋានច្បាស់អាចឱ្យតុលាការជឿបានថា ពិតជាមានអង្គហេតុនៃអំពើ លេងល្បែងស៊ីសង ដែលប្រព្រឹត្តដោយជនជាប់ចោទពិតប្រាកដមែន។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៥-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទូច បានឆ្លើយសារភាពសារភាពខាងលើឃើញថា: ចម្លើយសារភាពនេះមានភាពស៊ីសង្វាក់ទៅនឹងសំណុំរឿង និងឯកសារភស្តុតាងនានាក្នុងសំណុំរឿង និងមានមូលដ្ឋានច្បាស់អាចឱ្យតុលាការជឿបានថា ពិតជាមានអង្គហេតុនៃអំពើលេងល្បែងស៊ីសង ដែលប្រព្រឹត្តដោយជនជាប់ចោទ ពិតប្រាកដមែន។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៦-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វុធ បានឆ្លើយសារភាពសារភាពខាងលើឃើញថា: ចម្លើយសារភាពនេះមានភាពស៊ីសង្វាក់ទៅនឹងសំណុំរឿង និងឯកសារភស្តុតាងនានាក្នុងសំណុំរឿង និងមានមូលដ្ឋានច្បាស់អាចឱ្យតុលាការជឿបានថា ពិតជាមានអង្គហេតុនៃអំពើលេងល្បែងស៊ីសង ដែលប្រព្រឹត្តដោយជនជាប់ចោទ ពិតប្រាកដមែន។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៧-ផ្អែកតាមអំណានចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានា មានភាពស៊ីចង្វាក់គ្នាជាមួយរបាយការណ៍ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការនគរបាលខេត្តកំពង់ស្ពឺ អាចបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] ស៊ើ ភេទស្រី អាយុ៥២ឆ្នាំ ,ឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទូច ភេទស្រី អាយុ៤៨ឆ្នាំ បានធ្វើសកម្មភាពបើកកន្លែងលេងស៊ីសង និងលេងល្បែងស៊ីសង ពិតប្រាកដមែន។

៩-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ើ ភេទស្រី អាយុ៥២ឆ្នាំ ,ឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទូច ភេទស្រី អាយុ៤៨ឆ្នាំ ដែលបានធ្វើសកម្មភាពបើកកន្លែងលេងស៊ីសង និងលេងល្បែងស៊ីសង ដែលអំពើនេះមានធាតុផ្សំជាបទ

បើកកន្លែងលេងល្បែងស៊ី សង និងលេងល្បែងស៊ីសង ប្រព្រឹត្តនៅចំណុចភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ និងមាត្រា៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

១០-ជនជាប់ចោទឈ្មោះ [redacted] សើ ភេទស្រី អាយុ៤២ឆ្នាំ, ឈ្មោះ [redacted]វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ[redacted]អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទូច ភេទស្រី អាយុ៨៨ឆ្នាំ ក្នុងពេលប្រព្រឹត្តនិងក្រោយពេលប្រព្រឹត្តជននេះមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

១១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សើ ភេទស្រី អាយុ៤២ឆ្នាំ ,ឈ្មោះ [redacted]វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted]អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted]ទូច ភេទស្រី អាយុ៨៨ឆ្នាំ បានបង្ហាញឱ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទខាងលើនេះមានចេតនាទុច្ចរិត ដែលធ្វើឲ្យខូចរបៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា៤,៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង និងប៉ះពាល់ដល់បូរណភាពរបស់រូបវន្តបុគ្គលដទៃយ៉ាងធ្ងន់ធ្ងរ និងការអភិវឌ្ឍន៍សង្គម ដែលច្បាប់ការពារ។

១២-មានភស្តុតាង និងមានពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] សើ ភេទស្រី អាយុ៤២ឆ្នាំ,ឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទូច ភេទស្រី អាយុ៨៨ឆ្នាំ ពីបទៈ បើកកន្លែងលេងល្បែងស៊ីសង និងលេងល្បែងស៊ីសង ប្រព្រឹត្តនៅចំណុចភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ និងមាត្រា៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

១៣-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់អាចឱ្យតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការ មកពិចារណាក្នុងការសម្រេចសេចក្តី។

១៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំតុលាការនូវស្ថានសម្រាលឱ្យកូនក្តីខ្លួន និងសុំឱ្យដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាព ដើម្បីទៅរកស៊ីចិញ្ចឹមគ្រួសារ ហេតុដូចនេះគប្បីតុលាការលើកយកការសន្និដ្ឋានរបស់មេធាវី មកពិចារណាក្នុងការសម្រេចសេចក្តី។

១៥-ជនជាប់ចោទឈ្មោះ [redacted] សើ, [redacted]វុធ, ហេ អាង និងឈ្មោះ [redacted] ទូច បានចូលបង្ហាញខ្លួននៅពេលសវនាការ គប្បីតុលាការចេញសាលក្រមចំពោះមុខជនជាប់ចោទ តាមប្បញ្ញត្តិមាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៦-ជនជាប់ចោទឈ្មោះ [redacted] សើ ភេទស្រី អាយុ៤២ឆ្នាំ,ឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣៣ឆ្នាំ,ឈ្មោះ [redacted]អាង ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted]ទូច ភេទស្រី អាយុ៨៨ឆ្នាំ មិនទាន់មានការផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ឆ្នាំ មុនអំពើល្មើស គប្បីតុលាការពិចារណានិងសម្រេចសេចក្តីតាមបញ្ញត្តិមាត្រា ១០៦ និងមាត្រា ១០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

**I-ផ្តន្ទាទោសលើជនជាប់ចោទ ៖**

ក.ឈ្មោះ [redacted] សើ ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ)

ខ.ឈ្មោះ [redacted]វុធ ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ)



Scanned with CamScanner

គ.ឈ្មោះ [redacted] អាង ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ)

ឃ.ឈ្មោះ [redacted] ទូច ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១(មួយ)ឆ្នាំ **តែទោសនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ០៤(បួន)ខែ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ទោសនៅសល់ព្យួរធម្មតា** ពីបទៈ បើកកន្លែងលេងល្បែងស៊ីសង និងលេងល្បែងស៊ីសង ប្រព្រឹត្តនៅចំណុចភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ និងមាត្រា៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង និងមាត្រា១០៦ និងមាត្រា១០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**II**-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] សើ ឈ្មោះ [redacted] វុធ ឈ្មោះ [redacted] អាង និងឈ្មោះ [redacted] ទូច និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]